# អប្បបរិមាបំព្រួញលែងបាន
# Irreducible Minimum

## សេចក្តីសង្ខេបៈ

បញ្ញត្តិទាំងអស់របស់ព្រះជាម្ចាស់អាចត្រូវបានសង្ខេបមកត្រឹមនេះៈ យើងត្រូវស្រលាញ់ព្រះជាម្ចាស់ និងអ្នកជិតខាងរបស់យើង។ របៀបដ៏ចម្បងដែលយើងបង្ហាញចេញសេចក្តីស្រលាញ់របស់យើងចំពោះព្រះជាម្ចាស់ គឺតាមរយៈស្រលាញ់"អ្នកជិតខាង"ដែលព្រះអង្គដាក់នៅក្នុងជីវិតរបស់យើង។ ប្រសិនបើយើងធ្វេសប្រហែសនឹងសេចក្តីស្រលាញ់ចំពោះអ្នកដទៃនេះ សេចក្តីស្រលាញ់របស់ព្រះជាម្ចាស់មិនមាននៅក្នុងយើងទេ។

## គំនិតចម្បងៈ

១. បញ្ញត្តិធំជាងគេបំផុតគឺស្រលាញ់ព្រះជាម្ចាស់ និងស្រលាញ់អ្នកជិតខាងរបស់យើងដូចខ្លួនឯង។ ទោះបីយ៉ាងណាក៏ដោយ ក្រឹត្យវិន័យត្រូវបានសង្ខេបចុងក្រោយមកត្រឹមស្រលាញ់អ្នកជិតខាង។

២. សេចក្តីស្រលាញ់របស់យើងចំពោះព្រះជាម្ចាស់ត្រូវបានបង្ហាញចេញតាមរយៈការស្តាប់បង្គាប់របស់យើង ដែលជាការធ្វើតាមបំណងព្រះហឫទ័យរបស់ព្រះវរបិតា។

៣. ប្រសិនបើយើងធ្វេសប្រហែសចំពោះសេចក្តីត្រូវការរបស់មនុស្សដទៃទៀត សេចក្តីស្រលាញ់របស់ព្រះជាម្ចាស់មិនមាននៅក្នុងយើងទេ។

៤. លក្ខណៈដែលមិនប្រែប្រួលនៃរូបអង្គរបស់ព្រះជាម្ចាស់នៅក្នុងយើង គឺសេចក្តីស្រលាញ់បង្ហាញចេញតាមរយៈការប្រព្រឹត្តិចំពោះមនុស្សដទៃទៀត។

## លទ្ធផលៈ

១. ឥឡូវនេះៈ

ក. យល់ និងនិយាយប្រាប់គំនិតចម្បងរបស់មេរៀន ដោយប្រើពាក្យរបស់ខ្លួនគេ។

ខ. រៀបចំផែនការ និងអនុវត្តសកម្មភាពបម្រើថ្មីមួយដោយសេចក្តីស្រលាញ់ ជាការឆ្លើយតបទៅនឹងអប្បបរិមាបំព្រួញលែងបាននៃក្រឹត្យវិន័យរបស់ព្រះជាម្ចាស់នៅក្នុងរយៈពេល ២៤ ម៉ោងទៀត។

២. ទៅមុខទៀត

ក. ស្គាល់របៀបដែលពួកគេកំពុងធ្វេសប្រហែសនឹងសេចក្ដីត្រូវការរបស់មនុស្សដទៃទៀត ប្រែចិត្ត និងប្ដេជ្ញាចិត្តធ្វើឱ្យរបៀបវារៈទាំងមូលរបស់ព្រះជាម្ចាស់រីកចម្រើនឡើងចេញពីការយល់ដឹងថ្មីៗ។

ខ. ធ្វើជាអ្នកដឹកនាំដើម្បីបណ្តុះបណ្តាលអ្នកជឿដទៃទៀតសម្រាប់កិច្ចការបម្រើដោយសេចក្ដីស្រលាញ់ ជាផ្នែកមួយនៃដំណើរការបង្កើតសិស្សរបស់ពួកគេ ដើម្បីសម្រេចបញ្ញត្តិឱ្យស្រលាញ់ព្រះជាម្ចាស់ និងអ្នកជិតខាងរបស់យើង។

# អប្បបរិមាបំព្រួញលែងបាន

## គ្រោងមេរៀន

### ១. រំឭកមេរៀនឡើងវិញ

### ២. សេចក្ដីផ្ដើម

### ៣. ខគម្ពីរគន្លឹះ: ១ យ៉ូហាន ៣:១៧

ក. តើការស្រលាញ់ព្រះជាម្ចាស់ និងការស្រលាញ់អ្នកដទៃមានទំនាក់ទំនងជាមួយគ្នាយ៉ាងដូចម្ដេច?

ខ. តើលោកអ្នកអាចធ្វើជាសិស្សបានទេ ប្រសិនបើលោកអ្នកយកចិត្តទុកដាក់អំពីភាពខាងវិញ្ញាណ ប៉ុន្តែមិនយកចិត្តទុកដាក់ចំពោះសេចក្ដីត្រូវការខាងសាច់ឈាម និងខាងសង្គមរបស់អ្នកដទៃទៀត?

### ៤. សាសន៍សាម៉ារីដ៏សប្បុរស (លូកា ១០:២៥-៣៧)



ក. តើសំណួរពីរដែលព្រះយេស៊ូវឆ្លើយមានអ្វីខ្លះ?

ខ. តើយើងឆ្លើយទូទៅចំពោះសំណួរទាំងពីរនេះយ៉ាងដូចម្ដេច?

គ. តើព្រះយេស៊ូវឆ្លើយយ៉ាងដូចម្ដេចទៅកាន់សំណួរទីមួយ?

ឃ. តើព្រះយេស៊ូវឆ្លើយយ៉ាងដូចម្ដេចទៅកាន់សំណួរទីពីរ?

**៥. តើពាក្យអ្វីខ្លះដែលត្រូវបានប្រើសម្រាប់ក្រឹត្យវិន័យនៃសេចក្ដីស្រលាញ់?**

ក. យ៉ូហាន ១៥:១២

ខ. កាឡាទី ៦:២

គ. យ៉ាកុប ២:៨

ឃ. ម៉ាថាយ ២២:៣៦-៤០

ង. លូកា ៦:៣១

**៦. បណ្ដាក្រឹត្យវិន័យ និងអស់ទាំងទំនាយហោរាសង្ខេបមកយ៉ាងដូចម្ដេច?**

ក. ម៉ាថាយ ២២:៣៦-៤០

ខ. ម៉ាកុស ១២:២៨-៣១, ៣៣

គ. លូកា ១០:២៧

ឃ. ម៉ាថាយ ៧:១២

ង. រ៉ូម ១៣:៩-១០

ច. កាឡាទី ៥:១៣-១៤

## ៧. តើ "អប្បបរិមាចាំបាច់លែងបាន" នៃក្រឹត្យវិន័យរបស់ព្រះជាម្ចាស់គឺជាអ្វី?

## ៨. ការយល់ដឹងអំពីអប្បបរិមាចាំបាច់លែងបាន?

តើបទគម្ពីរទាំងនេះពន្យល់យ៉ាងដូចម្ដេចអំពីមូលហេតុដែលបញ្ញត្តិឱ្យស្រលាញ់អ្នកជិតខាងសង្ខេប "បណ្ដាក្រឹត្យវិន័យ និងអស់ទាំងទំនាយហោរា"?

*យ៉ាកុប ១:២៧*

*១យ៉ូហាន ៤:២០-២១*

តើព្រះយេស៊ូវរំពឹងចង់បានអ្វីពីអ្នកដើរតាមព្រះអង្គ? តើគុណធម៌អ្វីដែលត្រូវការបំផុតសម្រាប់ការបម្រើ? តើអ្វីធ្វើឱ្យមានការខុសប្លែកគ្នារវាងការស្ដាប់បង្គាប់ក្រឹត្យវិន័យដោយខ្វាក់ភ្នែក និងការបម្រើដែលចេញពីចិត្តស្រលាញ់?

*ម៉ាថាយ ៥:៤៣-៤៥*

*កូល៉ុស ៣:១២-១៤*

*១ យ៉ូហាន ៤:១៦*

## ៩. ការពង្រឹងគំនិតគន្លឹះឡើងវិញ

## ១០. ផែនការអនុវត្ត

ក. ការឆ្លុះបញ្ចាំង: តើលោកអ្នកអាចធ្វើអ្វីបាន ដើម្បីបង្ហាញចេញសេចក្តីស្រលាញ់របស់ព្រះជាម្ចាស់ចំពោះ "អ្នកជិតខាង"តាមរបៀបមួយថ្មីនៅថ្ងៃនេះ?

ខ. ជាក់លាក់:

- អ្វី
- នរណា
- នៅពេលណា
- នៅកន្លែងណា

គ. ចែកចាយផែនការរបស់លោកអ្នកជាមួយអ្នកផ្សេងទៀត ហើយអធិស្ឋានសម្រាប់គ្នាទៅវិញទៅមក។

# អព្ភូតរិមាបំព្រួញលែខបាន

## មេរៀន

ព្រះគម្ពីរប្រាប់នៅក្នុង ១ យ៉ូហាន ៣:១៧ ថា"បើអ្នកណាមានភោគសម្បត្តិរបស់លោកិយនេះ ហើយឃើញបងប្អូនណាដែលខ្វះខាត តែមិនចេះអាណិតមេត្តាសោះ នោះធ្វើដូចម្តេចឱ្យសេចក្តីស្រឡាញ់នៃព្រះបានស្ថិតនៅក្នុងអ្នកនោះបាន"។ ការស្រលាញ់ព្រះជាម្ចាស់ និងការស្រលាញ់មនុស្សមានទំនាក់ទំនងជាមួយគ្នាយ៉ាងខ្លាំង។ ប្រសិនបើសេចក្តីស្រលាញ់របស់ព្រះជាម្ចាស់មាននៅក្នុងយើង យើងបម្រើបងប្អូនរបស់យើង អ្នកជិតខាងរបស់យើងដែលខ្វះខាត។ យើងបម្រើគេមិនមែនដោយព្រោះតែជាកាតព្វកិច្ចប៉ុណ្ណោះទេ ប៉ុន្តែយើងបម្រើគេ ដោយព្រោះតែសេចក្តីស្រលាញ់ និងសេចក្តីអាណិតអាសូររបស់ព្រះជាម្ចាស់ជម្រុញយើង។ តាមពិតទៅ ខគម្ពីរនេះសួរថា តើយើងអាចធ្វើជាសិស្សរបស់ព្រះយេស៊ូវបានដែរឬទេ ប្រសិនបើយើងមិនមានចិត្តអាណិតអាសូរ មិនបង្ហាញចេញព្រះហឫទ័យយកចិត្តទុកដាក់របស់ព្រះជាម្ចាស់ចំពោះសេចក្តីត្រូវការខាងសាច់ឈាម និងខាងសង្គមរបស់មនុស្សដែលខ្វេចខ្វាំ? ផ្ទុយទៅវិញ នៅពេលដែលយើងបម្រើអ្នកជិតខាងរបស់យើងដែលខ្វះខាត សេចក្តីស្រលាញ់របស់ព្រះជាម្ចាស់នៅក្នុងយើងហូរហៀរចេញមកដល់អ្នកនោះ។ ព្រះយេស៊ូវបានបញ្ជាក់ថា គេស្គាល់សិស្សរបស់ព្រះអង្គតាមរយៈសេចក្តីស្រលាញ់! សេចក្តីស្រលាញ់គឺជាអ្នកកំណត់អត្តសញ្ញាណឱ្យសិស្សរបស់ព្រះយេស៊ូវគ្រីស្ទ។ សូមមើលព្រះបន្ទូលរបស់ព្រះអង្គដែលបានកត់ត្រានៅក្នុងយ៉ូហាន ១៣:៣៤-៣៥:

> *ខ្ញុំឱ្យសេចក្តីបញ្ញត្តិ១ថ្មីដល់អ្នករាល់គ្នា គឺឱ្យអ្នករាល់គ្នាស្រឡាញ់គ្នាទៅវិញទៅមក ត្រូវឱ្យស្រឡាញ់គ្នា ដូចជាខ្ញុំបានស្រឡាញ់អ្នករាល់គ្នាដែរ គេនឹងដឹងថា អ្នករាល់គ្នាជាសិស្សរបស់ខ្ញុំ ដោយសារសេចក្តីនេះឯង គឺដោយអ្នករាល់គ្នាមានសេចក្តីស្រឡាញ់ដល់គ្នាទៅវិញទៅមក។*

តាមរយៈការឆ្លុះបញ្ចាំងពីលក្ខណៈរបស់ព្រះជាម្ចាស់នេះ មនុស្សនឹងដឹងថា យើងគឺជាសិស្សរបស់ព្រះយេស៊ូវ។ យើងត្រូវស្រលាញ់ និងឱ្យបានដូចជាព្រះគ្រីស្ទ នៅក្នុងគ្រួសារ នៅកន្លែងធ្វើការ និងនៅកន្លែងរកស៊ីរបស់យើង ព្រមទាំងនៅតាមកន្លែងសាធារណៈផ្សេងទៀត។ យើងត្រូវស្រលាញ់ឱ្យដូចជាព្រះអង្គ ហើយតាមរយៈនោះ យើងតំណាងឱ្យរាជ្យរបស់ព្រះអង្គនៅក្នុងជីវិតរបស់យើង។

## សាសន៍សាម៉ារីដ៏សប្បុរស

នៅពេលមួយ មានបណ្ឌិតក្រឹត្យវិន័យជនជាតិយូដាម្នាក់បានសួរព្រះយេស៊ូវថា "តើត្រូវឱ្យខ្ញុំធ្វើដូចម្ដេច ដើម្បីឱ្យបានជីវិតអស់កល្បជានិច្ច?"។ ដោយមានប្រាជ្ញា ព្រះយេស៊ូវបានសួរអ្នកនោះវិញថា "ក្នុងក្រឹត្យវិន័យ តើមានកត់ទុកយ៉ាងដូចម្ដេច?"។ បណ្ឌិតខាងវិន័យនោះបានឆ្លើយថា "ឯងត្រូវស្រឡាញ់ព្រះអម្ចាស់ជាព្រះនៃឯង អោយអស់អំពីចិត្ត អស់អំពីព្រលឹង អស់អំពីកំឡាំង ហើយអស់អំពីគំនិតឯង ព្រមទាំងអ្នកជិតខាង ដូចខ្លួនឯងដែរ"។ ព្រះយេស៊ូវបានប្រាប់បុរសនោះឆ្លើយបានត្រឹមត្រូវហើយ និងមានបន្ទូលទៀតថា "ចូរអ្នកធ្វើដូច្នោះចុះ នោះអ្នកនឹងរស់នៅពិត"។ ដោយចង់សំដែងខ្លួនជាអ្នកសុចរិត បណ្ឌិតខាងវិន័យនោះបានសួរសំណួរទីពីរដល់ព្រះយេស៊ូវ "តើអ្នកណាជាអ្នកជិតខាងខ្ញុំ?"។ ព្រះយេស៊ូវបានឆ្លើយ ដោយប្រាប់គាត់រឿងប្រៀបប្រដូចពីសាសន៍សាម៉ារីដ៏សប្បុរសម្នាក់។

រឿងប្រៀបប្រដូចដែលព្រះយេស៊ូវបានប្រាប់គឺជារឿងប្រៀបប្រដូចមួយដែលគេស្គាល់យ៉ាងច្បាស់នៅក្នុងបទគម្ពីរ។ រឿងនោះនិយាយអំពីបុរសម្នាក់កំពុងធ្វើដំណើរពីទីក្រុងមួយទៅកាន់ទីក្រុងមួយទៀត។ គាត់ត្រូវចោរប្លន់ វាយឱ្យរបួស និងទុកចោល។ មានសង្ឃមួយអង្គបានឃើញបុរសរងរបួសនោះ ប៉ុន្តែមិនបានឈប់ដើម្បីជួយទេ។ ពួកលេវីម្នាក់ក៏បានដើរហួសបុរសរងរបួសនោះដែរ។ ពួកគេប្រហែលជាកំពុងតែប្រញាប់ ពួកគេប្រហែលជាខ្លាចចោរប្លន់ ពួកគេប្រហែលជាមិនចង់ទៅជាស្មោកគ្រោក ប្រសិនបើបុរសនោះស្លាប់។ យើងមិនដឹងអំពីហេតុផលរបស់ពួកគេទេ ប៉ុន្តែយើងដឹងថា ពួកគេមិនបានជួយទេ។ បន្ទាប់មក មានសាសន៍សាម៉ារីម្នាក់បានមកដល់ ជាអ្នកមិនជឿដែលពួកយូដាស្អប់ដោយព្រោះតែគាត់មានគោលលទ្ធិខុសឆ្គង។ ទោះបីជាគាត់មានគោលលទ្ធិខុសឆ្គងស្របទៅតាមព្រះគម្ពីរក៏ដោយ គាត់បានប្រព្រឹត្តដោយត្រឹមត្រូវ ស្របទៅតាមព្រះយេស៊ូវ។ គាត់បានឈប់ បានរុំរបួសឱ្យបុរសនោះ បាននាំគាត់ទៅកាន់ផ្ទះសំណាក់ និងបានចេញថ្លៃចំណាយឱ្យគាត់។

ព្រះយេស៊ូវកំពុងតែប្រើរឿងប្រៀបប្រដូចនេះដើម្បីឆ្លើយនឹងសំណួរទីពីររបស់បណ្ឌិតខាងវិន័យនោះ និងសំណួរទីមួយរបស់គាត់ផងដែរ។ ចម្លើយទាំងពីរពាក់ព័ន្ធនឹងសេចក្តីស្រលាញ់ ហើយចម្លើយទាំងពីរខុសពីចម្លើយដែលយើងបានរំពឹងទុក។ ប្រសិនបើគេសួរយើងថា "តើខ្ញុំត្រូវធ្វើយ៉ាងដូចម្តេច ដើម្បីឱ្យបានសង្គ្រោះ?"។ ជាទូទៅ យើងបង្ហាញពួកគេបទគម្ពីរ និងនាំពួកគេអធិស្ឋានប្រែចិត្ត។ ប៉ុន្តែ លូកា ១០:២៧ ប្រាប់ថា "ស្រលាញ់ព្រះជាម្ចាស់ និងស្រលាញ់អ្នកជិតខាងរបស់ខ្លួន" ហើយ"ទៅធ្វើដូច្នោះចុះ"។ រឿងប្រៀបប្រដូចនេះពន្យល់ប្រាប់ថា "ធ្វើឱ្យច្រើនជាងនិយាយ! ចូរបង្ហាញចេញសេចក្តីស្រលាញ់របស់ព្រះជាម្ចាស់។ ចូរបង្ហាញព្រះហឫទ័យអាណិតអាសូរ និងព្រះហឫទ័យយកចិត្តទុកដាក់របស់ព្រះអង្គចំពោះអ្នកដែលខ្វេចខ្វាំ"។ ដូចគ្នាដែរ ប្រសិនបើគេសួរយើងថា "តើអ្នកណាជាអ្នកជិតខាងរបស់ខ្ញុំ?" ជាទូទៅ យើងឆ្លើយតបថា "អ្នកជិតខាង" គឺជាអ្នកដែលរស់នៅជិតយើង។ "អ្នកជិតខាង" នៅក្នុងសហគមន៍ជាមួយគ្នា

ធ្វើកិច្ចការសម្រាប់គ្នាទៅវិញទៅមក និងមានភាពស្រដៀងគ្នាខ្លះ។ ប៉ុន្តែ ចម្លើយនៅក្នុងលូកា ១០:៣៧ មិនបានលើកឡើងអំពីភាពដូចគ្នាខាងជនជាតិ សេដ្ឋកិច្ច ឬភូមិសាស្ត្រទេ។ "អ្នកជិតខាង" គឺជាអ្នកដែលព្រះជាម្ចាស់ដាក់នៅក្នុងជីវិតរបស់យើង ដែលខ្វះខាត ត្រូវការឱ្យយើងប្រព្រឹត្តដោយមេត្តាករុណា និងសេចក្តីស្រលាញ់។ ហើយយើងគឺជា "អ្នកជិតខាង" នៅពេលដែលយើងប្រព្រឹត្តដោយមេត្តាករុណា។

តើនេះអាចក្លាយទៅជាបុព្វហេតុដែលនាំឱ្យមានការពិភាក្សាខាងទេវសាស្ត្រដែរឬទេ? យើងត្រូវបានសង្គ្រោះដោយសារព្រះគុណ មិនមែនដោយសារការប្រព្រឹត្តិទេ! ប៉ុន្តែ បើសិនយើងមានជំនឿពិតប្រាកដមែន យើងនឹងបង្ហាញចេញទំនាក់ទំនងរបស់យើងជាមួយព្រះជាម្ចាស់ តាមរយៈរបៀបដែលយើងបង្ហាញសេចក្តីស្រលាញ់របស់យើងដល់អ្នកជិតខាង។ ប្រសិនបើយើងបែកអារម្មណ៍ ហើយពិភាក្សារឿងទេវសាស្ត្រ យើងប្រហែលជាធ្វើអ្វីដែលអ្នកមានវ័យក្មេងធ្វើនៅក្នុងម៉ាកុស ១០:១៧-២៣។ យើងប្រហែលជាមានទេវសាស្ត្រត្រឹមត្រូវ ប៉ុន្តែយើងប្រហែលជាប្រឆាំងនឹងការដែលព្រះជាម្ចាស់ចង់ឱ្យយើងធ្វើ គឺបង្ហាញសេចក្តីស្រលាញ់ និងព្រះហឫទ័យអាណិតអាសូររបស់ព្រះអង្គដល់អ្នកដទៃ។ ព្រះយេស៊ូវបានប្រើរឿងប្រៀបប្រដូចអំពីសេចក្តីស្រលាញ់ដោយហ៊ានលះបង់នេះជាផ្នែកមួយនៃចម្លើយរបស់ព្រះអង្គទៅកាន់សំណួរអំពីរបៀបដើម្បីឱ្យបានជីវិតអស់កល្បជានិច្ច។

## ពាក្យដែលត្រូវបានប្រើសម្រាប់ក្រឹត្យវិន័យនៃសេចក្តីស្រលាញ់

បញ្ញត្តិឱ្យស្រលាញ់ត្រូវបានមើលឃើញជាច្រើនដងនៅក្នុងព្រះគម្ពីរ។ ប្រសិនបើយើងមើលបទគម្ពីរប្រាំនៅក្នុងសញ្ញាថ្មីអំពី "ក្រឹត្យវិន័យនៃសេចក្តីស្រលាញ់" នេះ យើងអាចរកឃើញរបៀបផ្សេងៗដែលបទគម្ពីរយោងទៅរកក្រឹត្យវិន័យនោះ។ នៅក្នុងយ៉ូហាន ១៥:១២ ព្រះយេស៊ូវយោងទៅរក "សេចក្តីបញ្ញត្តិរបស់ខ្ញុំ" នៅពេលដែលព្រះអង្គប្រាប់ពួកសិស្សរបស់ព្រះអង្គឱ្យស្រលាញ់គ្នាទៅវិញទៅមក ដូចជាព្រះអង្គបានស្រលាញ់ពួកគេ។ កាឡាទី ៦:២ ប្រាប់យើងឱ្យសម្រេច "ក្រឹត្យវិន័យនៃព្រះគ្រីស្ទ" នៅពេលដែលយើងយកអាសាគ្នាទៅវិញទៅមក។ បញ្ញត្តិឱ្យស្រលាញ់អ្នកជិតខាងរបស់យើងដូចខ្លួនឯងត្រូវបានហៅថាក្រឹត្យវិន័យដ៏ប្រសើរនៅក្នុងយ៉ាកុប ២:៨។ "បញ្ញត្តិយ៉ាងសំខាន់" គឺស្រលាញ់ព្រះជាម្ចាស់ និងទីពីរ គឺស្រលាញ់អ្នកជិតខាងដូចខ្លួនឯង ដោយយោងទៅតាមម៉ាថាយ ២២:៣៦-៤០។ លូកា ៦:៣១ ដាស់តឿនយើងឱ្យប្រព្រឹត្តចំពោះអ្នកដទៃ ដូចដែលយើងចង់ឱ្យគេប្រព្រឹត្តចំពោះយើង។ នៅតាមកន្លែងជាច្រើននៅលើពិភពលោក បញ្ញត្តិនេះត្រូវបានគេស្គាល់ថាជា "ច្បាប់មាស"។ នៅក្នុងចំណោមបទគម្ពីរទាំងប្រាំនេះ បទគម្ពីរបួនបង្គាប់យើងឱ្យស្រលាញ់មនុស្សដទៃទៀត រីឯបទគម្ពីរមួយទៀតបង្គាប់យើងឱ្យស្រលាញ់ព្រះជាម្ចាស់ និងអ្នកជិតខាង។

មានបទគម្ពីរប្រាំមួយនៅក្នុងសញ្ញាថ្មីដែលសង្ខេបបញ្ញត្តិទាំងអស់របស់ព្រះជាម្ចាស់។ បទគម្ពីរទាំងនោះត្រូវបានហៅថាសេចក្តីសង្ខេប"បណ្តាក្រឹត្យវិន័យ និងអស់ទាំងទំនាយហោរា"។ បទគម្ពីរបីនៅក្នុងចំណោមបទគម្ពីរទាំងនោះប្រាប់ថា សេចក្តីសង្ខេបគឺឱ្យស្រលាញ់ព្រះជាម្ចាស់ និងស្រលាញ់អ្នកជិតខាង។ តាមពិតទៅ ម៉ាកុស ១២:២៩ ប្រាប់ថា "បញ្ញត្តិដែលសំខាន់ជាងគេ" គឺ "ត្រូវស្រឡាញ់ដល់ព្រះអម្ចាស់ ជាព្រះនៃឯងឱ្យអស់អំពីចិត្ត" ហើយបញ្ញត្តិទីពីរគឺស្រលាញ់អ្នកជិតខាងខ្លួន។ ប៉ុន្តែបទគម្ពីរបី*ផ្សេងទៀត*ប្រាប់ថា សេចក្តីសង្ខេបនៅក្នុងបទគម្ពីរគឺឱ្យស្រលាញ់អ្នកជិតខាងខ្លួន ប៉ុន្តែមិនមានប្រាប់អ្វីដែលព្រះយេស៊ូវបានហៅថា សំខាន់ជាងគេនៅក្នុងបញ្ញត្តិទាំងពីរ។ ហេតុអ្វីបានជាខុសគ្នា?

| ស្រលាញ់ព្រះជាម្ចាស់ និងអ្នកជិតខាង | ស្រលាញ់អ្នកជិតខាង |
|---|---|
| • ម៉ាថាយ ២២:៣៦-៤០ | • ម៉ាថាយ ៧:១២ |
| • ម៉ាកុស ១២:២៨-៣១, ៣៣ | • រ៉ូម ១៣:៩ |
| • លូកា ១០:២៧ | • កាឡាទី ៥:១៤ |

ហេតុអ្វី? ព្រះជាម្ចាស់ប្រហែលជាយល់ថា យើងនឹងគិតថា យើងបានសម្រេចក្រឹត្យវិន័យទាំងមូល នៅពេលដែលយើងស្រលាញ់ព្រះអង្គ ព្រមទាំងគិតថា ការស្រលាញ់ព្រះជាម្ចាស់ធ្វើឱ្យអ្វីៗផ្សេងទៀតសម្រេច រួមបញ្ចូលទាំងការស្រលាញ់អ្នកជិតខាងរបស់យើង។ ខ្ញុំជឿថា ព្រះជាម្ចាស់ចង់ឱ្យយើងចាប់អារម្មណ៍ និងចង់សង្កត់ធ្ងន់ថា យើង*មិនអាច*ស្រលាញ់ព្រះអង្គពិតប្រាកដ ដោយមិនស្រលាញ់អ្នកជិតខាងរបស់យើងបាននោះទេ។ ការស្រលាញ់អ្នកជិតខាងរបស់យើងគឺជារបៀបចម្បងដែលព្រះជាម្ចាស់ចង់ឱ្យយើងបង្ហាញចេញសេចក្តីស្រលាញ់របស់យើងចំពោះព្រះអង្គ។ ការស្រលាញ់ព្រះជាម្ចាស់គឺជាបញ្ញត្តិដែលសំខាន់ជាងគេ ហើយការស្រលាញ់អ្នកជិតខាងរបស់យើងគឺជាការបង្ហាញចេញដែលសំខាន់ជាងគេ។ ដូច្នេះហើយ ការស្រលាញ់អ្នកជិតខាងរបស់យើងគឺជាសេចក្តីសង្ខេបបញ្ញត្តិទាំងអស់របស់ព្រះជាម្ចាស់។ នេះគឺជាសេចក្តីសង្ខេបដែលមិនអាចសង្ខេបតទៅទៀតបាន។

## អប្បបរិមាបំពេញលែងបាន

តាមរយៈបញ្ញត្តិសង្ខេបឱ្យស្រលាញ់អ្នកជិតខាងខ្លួន ព្រះជាម្ចាស់បានប្រទានឱ្យយើងនូវអប្បបរិមាបំពេញលែងបាននៃបញ្ញត្តិទាំងអស់របស់ព្រះអង្គ។ អប្បបរិមាបំពេញលែងបានគឺជាសេចក្តីសង្ខេបអ្វីមួយដែលជាមូលដ្ឋានគ្រឹះបំផុត។ នោះគឺជាសេចក្តីសង្ខេបដែលសាមញ្ញជាងគេ។ នៅក្នុងករណីនេះ មានន័យថា សេចក្តីសង្ខេបឱ្យស្រលាញ់ព្រះជា

ម្ចាស់ និងអ្នកជិតខាង ត្រូវបានបំពេញថែមទៀតមកត្រឹមការបង្ហាញដែលតូចជាងគេបំផុត គឺស្រលាញ់អ្នកជិតខាង (សម្រាប់អ្នកដែលចង់យល់ច្រើនថែមទៀតអំពីអប្បបរិមាបំពេញលែងបាន ឧទាហរណ៍ដទៃទៀតត្រូវបានផ្តល់ជូននៅចុងបញ្ចប់នៃមេរៀននេះ)។

មានបទគម្ពីរដទៃទៀតដែលបញ្ជាក់អំពីអប្បបរិមាបំពេញលែងបាននៃបញ្ញត្តិរបស់ព្រះជាម្ចាស់។ យ៉ាកុប ១:២៧ ប្រាប់ថា សាសនាដែលបរិសុទ្ធ និងឥតសៅហ្មងគឺមើលថែក្មេងកំព្រា និងស្ត្រីមេម៉ាយដែលមានសេចក្តីវេទនា។ ១ យ៉ូហាន ៣:១៧ ប្រាប់ដោយប្រយោលថា យើងមិនមានសេចក្តីស្រលាញ់ព្រះជាម្ចាស់នៅក្នុងយើងទេ ប្រសិនបើយើងមិនធ្វើអ្វីដែលយើងអាចធ្វើបាន ដើម្បីបំពេញសេចក្តីត្រូវការរបស់បងប្អូន។ ១ យ៉ូហាន ៥:៣ ឱ្យនិយមន័យសេចក្តីស្រលាញ់ថាជាការកាន់តាមអស់ទាំងបញ្ញត្តិរបស់ព្រះជាម្ចាស់ គឺយើងបង្ហាញចេញសេចក្តីស្រលាញ់របស់យើងចំពោះព្រះវរបិតានៃយើង តាមរយៈ*ការធ្វើតាម*បំណងព្រះហឫទ័យរបស់ព្រះអង្គ។

យើងស្រលាញ់អ្នកដទៃទៀត ដោយព្រោះនោះគឺជាអ្វីដែលព្រះជាម្ចាស់បង្គាប់យើងឱ្យធ្វើ ប៉ុន្តែសេចក្តីស្រលាញ់លើសជាងការស្តាប់បង្គាប់តាមក្រឹត្យវិន័យដោយខ្វាក់ភ្នែកទៅទៀត។ ការស្រលាញ់អ្នកដទៃទៀតលើសជាងកាតព្វកិច្ច អារម្មណ៍ ឬការសម្រេចចិត្តទៅទៀត។ ការបម្រើ និងសេចក្តីស្រលាញ់របស់យើងដល់អ្នកជិតខាងគួរតែកើតចេញពីចិត្តស្រលាញ់ ដែលព្រះជាម្ចាស់អភិវឌ្ឍនៅក្នុងយើង។ ១ កូរិនថូស ១៣ ប្រាប់យើងថា បើគ្មានសេចក្តីស្រលាញ់ទេ នោះអំណោយទានខាងវិញ្ញាណ ជំនឿដ៏ធំ ការប្រព្រឹត្តិដ៏អស្ចារ្យ ទង្វើសប្បុរសធម៌ និង សូម្បីតែលះបង់ជីវិតសម្រាប់ជំនឿ ក៏គ្មានផលប្រយោជន៍អ្វីដែរ។ ការប្រព្រឹត្តិដោយសេចក្តីស្រលាញ់ និងដោយចិត្តមេត្តា ធ្វើឡើងដោយសិស្សរបស់ព្រះយេស៊ូវដោយមានចិត្តឆ្លុះបញ្ចាំងឱ្យឃើញព្រះហឫទ័យអាណិតអាសូររបស់ព្រះគ្រីស្ទ។ សេចក្តីស្រលាញ់បែបនេះអត់ធ្មត់ មិនចេះឈ្នានីស មិនចេះអួតខ្លួន មិនដែលមានចិត្តធំ មិនដែលប្រព្រឹត្តបែបមិនគួរសម មិនដែលរកប្រយោជន៍ផ្ទាល់ខ្លួន មិនរហ័សខឹង មិនប្រកាន់ទោស មិនដែលអរសប្បាយចំពោះសេចក្តីទុច្ចរិតឡើយ គឺអរសប្បាយតែនឹងសេចក្តីស្មោះត្រង់វិញ ក៏គ្របបាំងទាំងអស់ ជឿទាំងអស់ សង្ឃឹមទាំងអស់ ហើយទ្រាំទ្រទាំងអស់។ លោកប៉ុលបានសង្ខេបថា សេចក្តីស្រលាញ់គឺជាសេចក្តីដែលវិសេសជាងគេ។ សេចក្តីស្រលាញ់គឺជាអប្បបរិមាដែលបំពេញលែងបាន។

ច្បាស់ណាស់ ព្រះជាម្ចាស់ចង់ឱ្យយើងបង្ហាញចេញសេចក្តីស្រលាញ់របស់ព្រះអង្គដោយភាពបរិសុទ្ធ និងបំណងចិត្តតែមួយដែលយើងមើលឃើញនៅក្នុងសញ្ញាថ្មីទាំងមូល។ ការស្រលាញ់មនុស្សដែលព្រះជាម្ចាស់នាំមកក្នុងជីវិតរបស់យើងគឺជារបៀបជាក់ស្តែង និងយ៉ាងសំខាន់ ដែលយើងបង្ហាញសេចក្តីស្រលាញ់របស់យើងចំពោះព្រះជាម្ចាស់។ យើងមិនអាចស្រលាញ់ព្រះជាម្ចាស់ ដោយមិនស្រលាញ់អ្នកជិតខាងខ្លួនបានទេ។ ស្រលាញ់ព្រះជាម្ចាស់គឺជាបញ្ញត្តិដែលសំខាន់ជាងគេ ហើយស្រលាញ់អ្នកជិតខាងខ្លួនគឺជាការបង្ហាញចេញដែលអស្ចារ្យជាងគេពីសេចក្តីស្រលាញ់របស់យើង

ចំពោះព្រះជាម្ចាស់ ។ ដូច្នេះហើយ ការស្រលាញ់អ្នកជិតខាងគឺជាសេចក្ដីសង្ខេបដែលជាមូលដ្ឋានគ្រឹះបំផុត ជាអប្បបរិមាបំព្រួញលែងបាននៃក្រឹត្យវិន័យទាំងអស់របស់ព្រះជាម្ចាស់ ។

តើបញ្ញត្តិនេះសំខាន់យ៉ាងណាទៅ? សូមមើលព្រះបន្ទូលរបស់ព្រះយេស៊ូវដែលបានកត់ត្រានៅក្នុងម៉ាថាយ ៧:២១-២៣:

"មិនមែនអស់អ្នកណាដែលគ្រាន់តែនិយាយមកខ្ញុំថា ឱព្រះអម្ចាស់ៗអើយ ដែលនឹងចូលទៅក្នុងនគរស្ថានសួគ៌នោះទេ គឺជាអស់អ្នកដែលធ្វើតាមព្រះហឫទ័យនៃព្រះវរបិតាដែលគង់នៅស្ថានសួគ៌វិញទេតើ នៅថ្ងៃនោះនឹងមានមនុស្សជាច្រើននិយាយមកខ្ញុំថា ឱព្រះអម្ចាស់ៗអើយ តើយើងខ្ញុំមិនបានទាយដោយនូវព្រះនាមទ្រង់ ហើយដេញអារក្ស ដោយនូវព្រះនាមទ្រង់ ព្រមទាំងធ្វើការឫទ្ធិបារមីជាច្រើន ដោយនូវព្រះនាមទ្រង់ទេឬអី នោះខ្ញុំនឹងនិយាយដោយត្រង់ថា អញមិនដែលបានស្គាល់ឯងរាល់គ្នាទេ នែពួកទទឹងច្បាប់អើយ ចូរថយចេញពីអញទៅ" ។

យើងត្រូវយល់អំពីបំណងព្រះហឫទ័យរបស់ព្រះវរបិតា! តើយើងអាចរំលងសេចក្ដីសំខាន់បំផុតដែលទ្រង់ចង់បាននោះបានដែរឬទេ? តើអាចទៅរួចទេ ដែលយើងធ្វើការអស្ចារ្យជាច្រើនដោយនៅក្នុងព្រះនាមរបស់ព្រះយេស៊ូវ ហើយព្រះអង្គមិនស្គាល់យើងនោះ? ព្រះបន្ទូលរបស់ព្រះយេស៊ូវនៅក្នុងម៉ាថាយ ៧:១២ ដែលនៅមុខបទគម្ពីរនេះផ្ដល់ឱ្យនូវការបញ្ជាក់មួយចំនួន "ដូច្នេះ អស់ទាំងការអ្វីដែលអ្នករាល់គ្នាចង់ឱ្យមនុស្សលោកប្រព្រឹត្តនឹងខ្លួននោះត្រូវឱ្យអ្នកប្រព្រឹត្តនឹងគេដូច្នោះដែរ ដ្បិតនេះឯងជាក្រឹត្យវិន័យ ហើយជាសេចក្ដីទំនាយរបស់ពួកហោរា" ។ម្ដងទៀត នេះគឺជាសេចក្ដីសង្ខេបបញ្ញត្តិរបស់ព្រះជាម្ចាស់ ។ ព្រះវរបិតាមានបំណងព្រះហឫទ័យឱ្យយើងធ្វើតាមក្រឹត្យវិន័យរបស់ព្រះអង្គ ហើយក្រឹត្យវិន័យរបស់ព្រះអង្គគឺឱ្យយើងប្រព្រឹត្តចំពោះមនុស្សដទៃទៀត ដូចដែលយើងចង់ឱ្យគេប្រព្រឹត្តចំពោះយើង ។

ចុងបញ្ចប់ យ៉ូហាន ១៣:៣៤-៣៥ បានពន្យល់ច្បាស់ចំណុចនេះ តាមរយៈបញ្ញត្តិរបស់ព្រះគ្រីស្ទឱ្យស្រលាញ់គ្នាទៅវិញទៅមក ដូចជាព្រះអង្គបានស្រលាញ់យើង ហើយដោយសារសេចក្ដីនេះ (អប្បបរិមាបំព្រួញលែងបាន) មនុស្សទាំងអស់នឹងដឹងថា យើងគឺជាសិស្សរបស់ព្រះអង្គ! ម្ដងនោះ មានគេនិយាយថា មហាបេសកកម្មឈរលើមហាបញ្ញត្តិ ។ នៅក្នុងម៉ាថាយ ២៨:១៨-២០ ដែលជាមហាបេសកកម្មរបស់ព្រះយេស៊ូវ ព្រះយេស៊ូវបានឱ្យសិទ្ធិអំណាចដល់ពួកអ្នកដើរតាមព្រះអង្គឱ្យទៅបញ្ចុះបញ្ចូលឱ្យមានសិស្សនៅគ្រប់ទាំងសាសន៍ បង្រៀនពួកគេឱ្យ

កាន់តាមបញ្ញត្តិទាំងអស់របស់ព្រះអង្គ។ មហាបញ្ញត្តិដាស់តឿនយើងឱ្យស្រលាញ់ព្រះជាម្ចាស់ និងអ្នកជិតខាងខ្លួន។ សេចក្តីស្រលាញ់គឺជាបុគ្គលិកលក្ខណៈមួយដែលខុសប្លែកពីគេ ហើយត្រូវតែជាស្នូលនៅក្នុងការបង្រៀនរបស់យើង ដូចជានៅក្នុងការបង្រៀនរបស់ព្រះយេស៊ូវដែរ។ សេចក្តីស្រលាញ់គឺជាមូលដ្ឋានគ្រឹះ និងមានសារៈសំខាន់។ សេចក្តីស្រលាញ់គឺជាអប្បបរិមាដែលបំព្រួញលែងបាន!

សង្ខេបៈ

- ព្រះជាម្ចាស់យកព្រះហឫទ័យទុកដាក់ចំពោះសេចក្តីត្រូវការខាងសាច់ឈាម ហើយព្រះអង្គចង់ឱ្យសិស្សរបស់ព្រះអង្គយកចិត្តទុកដាក់ចំពោះសេចក្តីត្រូវការទាំងនោះផងដែរ។
- ការស្រលាញ់អ្នកជិតខាងរបស់យើងពាក់ព័ន្ធនឹងសេចក្តីសង្គ្រោះរបស់យើង។ យើងមិនត្រូវបានសង្គ្រោះដោយសារការប្រព្រឹត្តិរបស់យើងទេ ប៉ុន្តែបើសេចក្តីស្រលាញ់របស់ព្រះជាម្ចាស់មាននៅក្នុងយើង ប្រាកដជាមានភស្តុតាងអំពីសេចក្តីស្រលាញ់របស់ព្រះជាម្ចាស់ នៅពេលដែលយើងស្រលាញ់អ្នកជិតខាងរបស់យើង។ ប្រសិនបើយើងធ្វេសប្រហែសចំពោះសេចក្តីត្រូវការរបស់មនុស្សដទៃទៀត សេចក្តីស្រលាញ់របស់ព្រះជាម្ចាស់មិនមាននៅក្នុងយើងទេ។
- អ្នកជិតខាងរបស់យើងគឺជាអ្នកដែលយើងជួប ហើយមានសេចក្តីត្រូវការដែលយើងអាចបម្រើបាន គឺនិយាយបានម្យ៉ាងទៀតថា យើងកំពុងធ្វើជា*អ្នកជិតខាង*ដល់អ្នកដទៃទៀត នៅពេលដែលយើងបម្រើពួកគេ។
- មានពាក្យផ្សេងៗគ្នាសម្រាប់ក្រឹត្យវិន័យនៃសេចក្តីស្រលាញ់នេះៈ សេចក្តីបញ្ញត្តិរបស់ខ្ញុំ ក្រឹត្យវិន័យនៃព្រះគ្រីស្ទ ក្រឹត្យវិន័យដ៏ប្រសើរ បញ្ញត្តិយ៉ាងសំខាន់ និងច្បាប់មាស។ ពាក្យផ្សេងៗគ្នាទាំងនេះបំពេញគ្នាទៅវិញទៅមក និងជួយយើងឱ្យយល់កាន់តែទូលំទូលាយអំពីសេចក្តីដែលព្រះគម្ពីរបង្រៀនអំពីក្រឹត្យវិន័យនៃសេចក្តីស្រលាញ់។
- សេចក្តីសង្ខេបជាមូលដ្ឋានគ្រឹះបំផុត ឬអប្បបរិមាដែលបំព្រួញលែងបាននៃក្រឹត្យវិន័យរបស់ព្រះជាម្ចាស់ គឺថា យើងបង្ហាញចេញសេចក្តីស្រលាញ់ចំពោះព្រះជាម្ចាស់ដែលគង់នៅក្នុងយើង តាមរយៈការស្រលាញ់អ្នកជិតខាងរបស់យើង។

មេរៀននេះមិនមែនគ្រាន់តែសិក្សាប៉ុណ្ណោះទេ គឺត្រូវយកមកអនុវត្តថែមទៀតផង! យើងអាចធ្វើកិច្ចការតូចតាច ដើម្បីស្តាប់បង្គាប់តាមសេចក្តីសង្ខេបបញ្ញត្តិរបស់ព្រះជាម្ចាស់ដែលជាមូលដ្ឋានគ្រឹះបំផុត គឺស្រលាញ់អ្នកជិតខាងរបស់យើង។ ដំបូង យើងអាចសួរព្រះជាម្ចាស់ថា ព្រះអង្គកំពុងដាក់នរណានៅក្នុងជីវិតរបស់យើងដើម្បីឱ្យយើងស្រលាញ់ និងអ្វីដែលយើងអាចធ្វើបានសម្រាប់ពួកគេដែលថ្មី ហើយពិតប្រាកដ។ តើយើងអាចធ្វើអ្វីបានដើម្បីបម្រើសេចក្តីត្រូវការខាងសាច់ឈាម ឬខាងសង្គមរបស់អ្នកជិតខាងយើងណាម្នាក់? វាជួយលោកអ្នក បើសិនជាលោកអ្នកសរសេរទុកគំនិតនេះ ប្រាប់អ្នកផ្សេងទៀតអំពីគំនិតនោះ ហើយអធិស្ឋានជាមួយគ្នា។

ព្រះអម្ចាស់អើយ ទូលបង្គំដឹងថា កាធ្វើតាមបំណងព្រះហឫទ័យរបស់ព្រះអង្គ និងការដែលព្រះអង្គស្គាល់ទូលបង្គំពាក់ព័ន្ធយ៉ាងជិតស្និទ្ធជាមួយ"ការស្រលាញ់អ្នកជិតខាងដូចខ្លួនឯង" លើសជាងដែលទូលបង្គំបានបង្ហាញចេញនៅក្នុងជីវិតរបស់ទូលបង្គំ។ សូមជួយទូលបង្គំឱ្យយល់របៀបដែលទូលបង្គំគួរតែធ្វើតាមបំណងព្រះហឫទ័យរបស់ព្រះអង្គ។ សូមជួយទូលបង្គំឱ្យស្រលាញ់ និងប្រព្រឹត្តចំពោះមនុស្សដទៃទៀត ដូចដែលទូលបង្គំចង់ឱ្យគេស្រលាញ់ និងប្រព្រឹត្តដាក់។ សូមជួយទូលបង្គំឱ្យចេះឈប់ មើល និងជួយអ្នកខ្វះខាត ដែលព្រះអង្គបានដាក់នៅក្នុងជីវិតរបស់ទូលបង្គំ ដោយព្រោះតែព្រះហឫទ័យអាណិតអាសូរ និងសេចក្តីស្រលាញ់របស់ព្រះអង្គ អាម៉ែន!

*កំណត់ចំណាំអំពីអប្បបរិមាដែលបំពេញលែងបាន*

- <u>ការទទួលខុសត្រូវ:</u> សូមពិចារណាកិច្ចការដែលនិយោជិកត្រូវធ្វើ ដើម្បីបំពេញតាមកិច្ចសន្យា មានទំនាក់ទំនងល្អនៅកន្លែងធ្វើការ និងទទួលបានប្រាក់បៀវត្ស ឬពិចារណាកិច្ចការដែលមនុស្សត្រូវធ្វើនៅផ្ទះ ដើម្បីឱ្យគ្រួសារមានសុភមង្គល ហើយគ្រប់គ្នាសប្បាយចិត្ត ឬពិចារណាអប្បបរិមាដែលត្រូវការដើម្បីធ្វើជាប្រជាពលរដ្ឋល្អ។ បញ្ជីកិច្ចការអប្បបរិមាគឺជា"បញ្ជីអប្បបរិមាដែលបំពេញលែងបាន"សម្រាប់និយោជិកល្អ សមាជិកគ្រួសារល្អ ឬប្រជាពលរដ្ឋល្អ។
- <u>គណិតវិទ្យា:</u> ពិចារណាអំពីសមីកា ឬប្រភាគ។ ឧទាហរណ៍ បំព្រួញ ៤/៦ ដោយយកចំនួនទាំងពីរមកចែកនឹង ២។ លទ្ធផលគឺ ២/៣ ដែលមានតម្លៃស្មើនឹង ៤/៦។ សិស្សមិនអាចបំព្រួញ ២/៣ តាមវិធីសាស្ត្រដដែលបានទេ។ ដូច្នេះហើយ ២/៣ គឺជា"អប្បបរិមាដែលបំព្រួញលែងបាន"។
- <u>ជីវវិទ្យា:</u> ការបកស្រាយមួយប្រឆាំងនឹងទ្រឹស្តីអំពីការវិវឌ្ឍន៍ត្រូវបានហៅថា "ភាពស្មុគស្មាញបំព្រួញលែងបាន"។ ជីវសរីរាង្គត្រូវការតួនាទីមួយចំនួនជាអប្បបរិមាដើម្បីរស់ ដូចជាការដកដង្ហើម ការបរិភោគជាដើម ។ល។ ព្រមទាំងត្រូវការរចនាសម្ព័ន្ធជាអប្បបរិមាផងដែរ ដូចជាភ្នាសកោសិកា ក្រូម៉ូ

ហ្សូមជាដើម ។ល ។ តួនាទី និងរចនាសម្ព័ន្ធនិមួយៗមានលក្ខណៈស្មុគស្មាញខ្លាំងណាស់ ដែលវិទ្យាសាស្ត្រមិនអាចយល់បានទេ ប៉ុន្តែសុទ្ធតែជាមូលដ្ឋានគ្រឹះ និងមានសារៈសំខាន់ ។


*By Bob Moffitt, Harvest Foundation*

*Last edited by Nadia Chandler and Karla Tesch, August, 2007.*



*Copyright 2007 by the Disciple Nations Alliance*



*701 N. 1st Street Phoenix, AZ  85004*

*email: bmoffitt@harvestfoundation.org*

*www.harvestfoundation.org and www.disciplenations.org*



*ការអនុញ្ញាតៈ លោកអ្នកត្រូវបានអនុញ្ញាត និងលើកទឹកចិត្តឱ្យថតចម្លង និងចែកចាយមេរៀននេះតាមទម្រង់ណាមួយក៏បាន តែសូមកុំកែន័យមេរៀន កុំគិតថ្លៃហួសពីលោកអ្នកចំណាយ និងកុំថតចម្លងច្រើនជាង ១០០០ ច្បាប់ ។*

## ធនធានល្អដែលបានផ្តល់ជាយោបល់ជូន៖

Moffitt, Bob, Tesch, Karla. *If Jesus Were Mayor: How Your Local Church Can Transform Your Community.* Oxford, UK: Monarch Books, 2006, pp. 87-97.

Moffitt, Bob. *What kind of churches and What Kind of Disciples?* A background paper.

Oliveira, Eli. *Irreducible Minimum.* An article.

Harvest Foundation. *Leadership Development Training Program.* www.harvestfoundation.org. Section: Materials, pp. 26-39.

Disciple Nations Alliance online course. www.disciplenations.org/resources/course. Section: *Wholistic Ministry*.